**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ : ១៧៤ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតគណៈកម្មាធិការគោលនយោបាយសារពើពន្ធ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នា នៃការកំណត់មុខទំនិញ និងប្រព័ន្ធលេខកូដ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈ-កម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា "គ.គ.ព." ដើម្បីពិនិត្យ សម្របសម្រួល និងលើកសំណើកែសម្រួលគោលនយោបាយសារពើពន្ធ ដោយឈរលើគោលការណ៍សមធម៌, សាមញ្ញភាព, តម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព។

## ជំពូកទី២

## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

គ.គ.ព. មានសមាសភាព ដូចខាងក្រោម÷

| | |
|---|---|
| ១.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២.រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤. តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦. តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨. តំណាងក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៩. តំណាងក្រសួងបរិស្ថាន | សមាជិក |
| ១០. តំណាងក្រសួងសុខាភិបាល | សមាជិក |
| ១១. តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ១២. តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៣. តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |
| ១៤. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥.អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

១៦.អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៧.អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

សមាសភាពជាក់ស្តែងនៃ គ.គ.ព. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.-**

គ.គ.ព. មានភារកិច្ច ដូចតទៅ÷

- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងគោលនយោបាយសារពើពន្ធ ព្រមទាំងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយខាងដើម
- ពិនិត្យ វាយតម្លៃ និងលើកសំណើកែសម្រួលមូលដ្ឋាននិងអត្រាពន្ធអាករគ្រប់ប្រភេទ ដោយអនុលោមតាមគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងកិច្ចព្រមព្រៀងនិងបទដ្ឋានគតិយុត្តអន្តរជាតិផ្សេងទៀតពាក់ព័ន្ធវិស័យសារពើពន្ធ និងពាណិជ្ជកម្មអន្តរជាតិ ដើម្បីធានាបាននូវបរិស្ថានធុរកិច្ចប្រកបដោយសមធម៌និងកិច្ចសម្រួលពាណិជ្ជកម្ម និងប្រសិទ្ធភាពនៃការកៀរគរចំណូលសារពើពន្ធ
- ពិនិត្យនិងផ្តល់អនុសាសន៍លើគោលនយោបាយពាក់ព័ន្ធសារពើពន្ធ តាមការកំណត់របស់រាជរដ្ឋាភិបាល។

ចំពោះបញ្ហាពាក់ព័ន្ធវិស័យសារពើពន្ធដែលមានវេទយិតភាពខ្ពស់ គ.គ.ព. អាចស្នើសុំទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច។

## ជំពូកទី៣

## ដំណើរការការងារ

**មាត្រា៤.-**

សមាសភាពនៃ គ.គ.ព.ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

ប្រធាន គ.គ.ព. ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានប្រចាំការត្រូវដឹកនាំអង្គប្រជុំ ជំនួស។

ប្រធាន គ.គ.ព. អាចអញ្ជើញអ្នកជំនាញ និងតំណាងក្រសួង ស្ថាប័នដែលមិនមែនជាសមាជិកនៃ គ.គ.ព. ចូលរួមប្រជុំតាមការចាំបាច់។

គ.គ.ព. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៥.-**

គ.គ.ព. មានលេខាធិការដ្ឋានមួយជាសេនាធិការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋាន គ.គ.ព. ។

**មាត្រា៦.-**

លេខាធិការដ្ឋាន គ.គ.ព. មានភារកិច្ច ដូចតទៅ÷

- សម្របសម្រួលការងាររដ្ឋបាល និងធានាកិច្ចដំណើរការរបស់ គ.គ.ព.
- សិក្សាស្រាវជ្រាវអំពីបទដ្ឋានគតិយុត្តពាក់ព័ន្ធគោលនយោបាយសារពើពន្ធ ព្រមទាំងនិន្នាការវិវឌ្ឍន៍នៃគោលនយោបាយសារពើពន្ធជាតិនិងអន្តរជាតិ និងពាណិជ្ជកម្មអន្តរជាតិ ដើម្បីធ្វើជាមូលដ្ឋានក្នុងការលើកសំណើកែលម្អគោលនយោបាយសារពើពន្ធ

- រៀបចំនិងលើកសំណើកែលម្អគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសារពើពន្ធ
- បូកសរុបនិងវាយតម្លៃលើការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសារពើពន្ធ
- បំពេញភារកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាន គ.គ.ព.។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៧.-**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ